

គោលនយោបាយសង្ខេប

# កសិរុក្ខកម្មដីទុកទំនេរ-ចម្ការវិលជុំ ដើម្បី និរន្តរភាពការប្រើប្រាស់ដីធ្លីនៅអាស៊ីអាគ្នេយ៍

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

រៀបចំដោយកម្មវិធីរបស់មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោកអាស៊ីអាគ្នេយ៍ (World Agroforestry Southeast Asia Regional Program)
រួមសហការជាមួយបណ្តាញព្រៃឈើសង្គមអាស៊ាន (ASEAN Social Forestry Network)

World Agroforestry Policy Brief No. 98

*Regrowth on swidden in Palawan, Philippines*

*រូបភាព៖ Wolfram Dressler*

គោលនយោបាយសង្ខេប

# កសិរុក្ខកម្មដីទុកទំនេរ-ចម្ការវិលជុំ ដើម្បី និរន្តរភាពការប្រើប្រាស់ដីធ្លីនៅអាស៊ីអាគ្នេយ៍

World Agroforestry

AWG-SF
ASEAN Working Group on Social Forestry

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

asean

រៀបចំដោយកម្មវិធីរបស់មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោកអាស៊ីអាគ្នេយ៍ (World Agroforestry Southeast Asia Regional Program)
រួមសហការជាមួយបណ្តាញព្រៃឈើសង្គមអាស៊ានអាស៊ាន (ASEAN Social Forestry Network)

# បញ្ជីពាក្យកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| **AMS** | (ASEAN Member State) រដ្ឋជាសមាជិកអាស៊ាន |
| **ASEAN** | (Association of Southeast Asian Nations) សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **ASFCC** | (ASEAN-Swiss Partnership on Social Forestry and Climate Change) ភាពជាដៃគូរអាស៊ាន-ស្វីសស្តីអំពីព្រៃឈើសង្គម និងការប្រែប្រួលអាកាសធាតុ |
| **AWG-SF** | (ASEAN Working Group on Social Forestry) បណ្តាញព្រៃឈើសង្គមអាស៊ាន |
| **NDCs** | (Nationally Determined Contributions) វិភាគទានអនុម័តថ្នាក់ជាតិនានា |
| **NDC** | (Nationally Determined Contributions) វិភាគទានអនុម័តថ្នាក់ជាតិ |
| **REDD+** | (Reducing emissions from deforestation and forest degradation) ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ |

ប្រព័ន្ធ កសិកម្ម ចម្ការវិលជុំដាំឆ្លាស់គ្នារវាងដំណាំស្បៀងអាហារប្រចាំឆ្នាំនិងរុក្ខជាតិយូរឆ្នាំដោយមានការរៀបចំដោយប្រុងប្រយ័ត្ននូវតំណភាពរុក្ខជាតិធម្មជាតិ។ ប្រព័ន្ធទាំងនេះ នៅតែត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយកសិករនៅតាមតំបន់ខ្ពង់រាប និងជាយព្រៃអាស៊ីអាគ្នេយ៍ ធ្វើឲ្យមាននិរន្តរភាពទាំង
សេវាកម្មអេកូឡូស៊ីនិងសង្គម។ ដំណើរការនៃចម្ការវិលជុំ គឺច្រើនតែរួមបញ្ចូលទាំងប្រព័ន្ធកសិរុក្ខកម្មដែលដីទុកទំនេរត្រូវបានដាំដុះប្រភេទឈើចម្រុះ ដែលមានប្រយោជន៍អាចរួមបញ្ចូលនៅក្នុងស្ថានប្រព័ន្ធព្រៃឈើ។ កសិរុក្ខកម្មទាំងនេះត្រូវបានរួមបញ្ចូលនៅក្នុងប្រព័ន្ធកសិកម្ម និងជាជម្រើសជាយុទ្ធសាស្ត្រជាក់ស្តែងសម្រាប់គ្រួសារតូចៗ ដោយរួមចំណែកធានាដល់សុវត្ថភាពស្បៀងអាហារ និងពិពិធកម្មផលិតកម្មនិងប្រាក់ចំណូល។ ប្រការនេះនឹងលើកកម្ពស់លទ្ធភាពស្តារឡើងវិញនូវសេដ្ឋកិច្ចជាមួយនឹងការផ្តល់ឲ្យនូវការស្តុកទុកកាបូនដ៏មានប្រសិទ្ធភាព និងសេវាកម្មបរិស្ថានដ៏មានសារៈសំខាន់។ ក៏ប៉ុន្តែបណ្តារដ្ឋាភិបាលនៅក្នុងតំបន់តែងតែមានចំណូលចិត្តគាំទ្រដល់ការពង្រីកប្រព័ន្ធឯកវប្បកម្មឯកទេសយ៉ាងលឿនរហ័សជាជាងការលើកទឹកចិត្តឲ្យមានការវិវត្តបន្តិចម្តងៗ។

| លេខ | សារជាគន្លឹះ | ការអនុវត្តគោលនយោបាយ |
|---|---|---|
| 1 | បណ្តារដ្ឋាភិបាលនៅក្នុងតំបន់ជាទូទៅមើលឃើញការធ្វើចម្ការវិលជុំថាជាការបំផ្លិចបំផ្លាញ៖ នេះជាមូលហេតុចម្បងនាំឲ្យមានភ្លើងឆេះព្រៃ ការកាប់បំផ្លាញព្រៃឈើ និងការធ្លាក់ចុះអន់ថយធនធានទឹកនិងដី។ ចម្ការវិលជុំត្រូវបានមើលឃើញថាគ្មានប្រសិទ្ធភាព និងមិនអាចលើកកម្ពស់កម្រិតជីវភាពរស់នៅឡើយ បើប្រៀបធៀបទៅនឹងកសិកម្មទំនើបប្រពលវប្បកម្ម។ | ការអនុវត្តចម្ការវិលជុំផ្តល់មកឲ្យនូវផលប្រយោជន៍ចម្រុះនៅក្នុងរូបភាពទេសភាពដែលមានមុខងារចម្រុះ ហើយគោលនយោបាយតម្រូវឲ្យមានការចាប់យកនូវទស្សនវិស័យនេះ។ |
| 2 | ដីទុកទំនេរត្រូវបានបណ្តារដ្ឋាភិបាលចាត់ទុកថាជាដីបោះបង់ចោល និងមិនអាចផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដោយផ្ទាល់បានឡើយ។ ដីទាំងនេះមិនត្រូវបានកំណត់ពីភាពខុសប្លែកគ្នានៅលើផែនទីឡើយ ហើយក៏មិនត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃរូបភាពទេសភាពកសិកម្មដែរ។ | គោលនយោបាយតម្រូវឲ្យមានការទទួលស្គាល់ដីទុកទំនេរចោលថាជាប្រភេទដីប្រើប្រាស់មានផលិតភាពផ្នែកសេដ្ឋកិច្ច ដែលផ្តល់នូវសេវាប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។ |
| 3 | ក្នុងប្រព័ន្ធចម្ការវិលជុំបែបប្រពៃណី ការដាំដុះលើដីទុកទំនេរចោលតាមរយៈកសិរុក្ខកម្ម គឺជាយុទ្ធសាស្ត្រពិពិធភាពសម្រាប់កសិករដែលកាត់បន្ថយបាននូវហានិភ័យនៃអសន្តិសុខសេដ្ឋកិច្ច និងស្បៀងអាហារ។ | កសិរុក្ខកម្មនៅក្នុងប្រព័ន្ធចម្ការវិលជុំអនុញ្ញាតឲ្យកសិករមានភាពឯករាជ្យជាងមុន ចំពោះការពឹងផ្អែកលើនិន្នាការទីផ្សារ ដោយបង្កើននូវការស្តារឡើងវិញនូវសេដ្ឋកិច្ច។ ការគាំទ្រគោលនយោបាយនេះត្រូវការចាំបាច់ដើម្បីជម្រុញដល់ការវិនិយោគដោយកសិករចម្ការវិលជុំ។ |
| 4 | ប្រព័ន្ធកសិរុក្ខកម្មដីទុកទំនេរ-ចម្ការវិលជុំ អនុញ្ញាតឲ្យមានការប្រើប្រាស់ដីប្រកបដោយនិរន្តរភាពជាអចិន្ត្រៃយ៍ដោយពុំមានការដុតព្រៃឬធ្វើឲ្យខូចដីឡើយ។ ប្រព័ន្ធនេះផ្តល់នូវការស្តុកទុកកាបូនដោយប្រសិទ្ធភាពនិងសេវាកម្មបរិស្ថានដ៏មានសារៈសំខាន់។ | គោលនយោបាយដែលមានប្រសិទ្ធភាពតម្រូវឲ្យមានការទទួលស្គាល់មុខងារសង្គមសេដ្ឋកិច្ច និងអេកូឡូស៊ីរបស់ប្រព័ន្ធកសិរុក្ខកម្មដីទុកទំនេរ-ចម្ការវិលជុំ។ |
| 5 | គោលនយោបាយទប់ស្កាត់ការធ្វើកសិកម្មចម្ការវិលជុំធ្វើឲ្យចុះខ្សោយនូវការអនុវត្តការដាំដុះលើដីទុកទំនេរ និងធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សទៅរកប្រព័ន្ធដំណាំនិងដើមឈើឯកវប្បកម្ម និងការធ្វើចម្ការជាជាងការគាំទ្រការវិវត្តបន្តិចម្តងៗនៃប្រព័ន្ធចម្ការវិលជុំ។ | ការផ្លាស់ប្តូរដែលមានការគាំទ្រឆ្ពោះទៅរកប្រព័ន្ធកសិរុក្ខកម្មនឹងធានាបាននូវការធ្វើឲ្យប្រសើរបំផុតនៃផលិតកម្ម ប្រាក់ចំណូល និងផលចំណេញផ្នែកបរិស្ថាន។ |



រូបភាព៖ World Agroforestry/Noviana Khususiyah



រូបភាព៖ World Agroforestry/Noviana Khususiyah

### កសិរុក្ខកម្មដីទុកចោលទំនេរចំការវិលជុំ

ចម្ការវិលជុំតែងត្រូវបានប្រើប្រាស់ដើម្បីផលិតចំណីអាហារមូលដ្ឋានសម្រាប់ការប្រើប្រាស់នៅក្នុងតំបន់ និងស្ទើរតែពុំមានបរិមាណសេសសល់សម្រាប់លក់ឡើយ។ ការដាំដុះលើដីទុកទំនេរ គឺជាយុទ្ធសាស្ត្ររបស់សហគមន៍ ដែលត្រូវបំពេញបន្ថែមទៅលើការអនុវត្តការធ្វើកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ វាដើរតួជាកត្តាកំណត់នៅក្នុងសេដ្ឋកិច្ចកសិកម្ម មិនត្រឹមតែតាមរយៈលំហូរសាច់ប្រាក់ជាធម្មតាពីបណ្តាមុខទំនិញពាណិជ្ជកម្មនោះទេ ប៉ុន្តែវាក៏ជាទ្រនាប់ការពារហានិភ័យផងដែរ នៅក្នុងគ្រាស្ថានភាពតានតឹងតាមរយៈភាពសម្បូរបែបនៃស្បៀងអាហារនិងរបបអាហារ ( Michon 2005, van Noordwijk et al 2008)។ កសិរុក្ខកម្មតែងជាផ្នែកមួយនៃប្រព័ន្ធចម្ការវិលជុំ។ ដីទុកទំនេរ ត្រូវបានដាំនូវដើមឈើដែលមានប្រយោជន៍ខុសៗគ្នា ដែលតែងតែរួមបញ្ចូលជាមួយនឹងស្ថានប្រព័ន្ធព្រៃឈើ។ នៅប្រទេសឥណ្ឌូនេស៊ី សហគមន៍ដាំដំណាំហូបផ្លែកៅស៊ូ កាហ្វេ កាកាវ និងផ្តៅ ដែលបង្កើតឲ្យមានកសិរុក្ខកម្មចម្រុះទៅលើដីទំនេរ-ចម្ការវិលជុំដែលមានការគ្រប់គ្រង។ ទោះបីជាមានលក្ខណៈប្រហាក់ប្រហែលទៅនឹងព្រៃឈើយ៉ាងណាក៏ដោយ ក៏កសិរុក្ខកម្មទាំងនេះមានការរួមបញ្ចូលគ្នាយ៉ាងពេញលេញជាមួយនឹងប្រព័ន្ធកសិកម្មតាមមូលដ្ឋាន។ នៅហ្វីលីពីន ចម្ការកសិកម្មខ្នាតតូចដែលទុកឲ្យរុក្ខជាតិលូតលាស់ឡើងវិញដោយឯកឯងជាច្រើនកំពុងមានការថយចុះ ប៉ុន្តែព្រៃដែលដុះលូតលាស់ឡើងវិញតាមធម្មជាតិលើដីទុកទំនេរ-ចម្ការវិលជុំ ជួយបង្កើនការត្រួតពិនិត្យកត្តាចង្រៃនានា ជំងឺ និងស្មៅចង្រៃ រក្សាទុកដីសម្រាប់ធ្វើជាដីវាលស្មៅ និងលែងសត្វសម្រាប់ជាក្រវាត់ការពារ និងរក្សាវាសម្រាប់ធ្វើជាប្រភពអុសដុត ចំណីអាហារ និងរុក្ខជាតិឱសថ ( Lasco et al 2001)។ នៅប្រទេសវៀតណាម កសិរុក្ខកម្មបានក្លាយទៅជាលក្ខណៈពិសេសនៃទេសភាពព្រៃឈើនិងកសិកម្មតាំងពីមុនសម័យទំនើបមកម្លេះ ប៉ុន្តែការស្រាវជ្រាវវិទ្យាសាស្ត្រទើបតែចាប់ផ្តើមនៅដើមទសវត្សរ៍1970 ដែលនាំឲ្យមានការបន្សាំនៃប្រព័ន្ធតាមបែបប្រពៃណីមួយចំនួន ជាពិសេសចម្ការវិលជុំកសិរុក្ខកម្ម និងការណែនាំនូវប្រព័ន្ធថ្មីដូចជាការដាំដំណាំចន្លោះដើមឈើ ការដាំឈើនៅតាមព្រំដី និង "taungya"[1] (Snelder and Lasco 2008)។

## ផលស្រាវជ្រាវ

### 1. បម្លាស់ប្តូរដីទុកទំនេរ-ចម្ការវិលជុំ

ការផ្លាស់ប្តូរជាសំខាន់កើតមាននៅក្នុងប្រព័ន្ធចម្ការវិលជុំនៅពេលដែលតម្លៃសេដ្ឋកិច្ច នៃ ផលិតកម្មដើមឈើមានការកើនឡើង ឧទាហរណ៍ដូចជា កៅស៊ូ និងកាហ្វេជាដើម ហើយក្នុងខណៈដែលដំណាំពាណិជ្ជកម្មត្រូវបានបញ្ចូលនៅក្នុងដំណាំស្បៀងអាហារនោះ។ នៅពេលការផ្លាស់ប្តូរទាំងនេះដំណើរការដោយប្រសិទ្ធភាព ដំណាំពាណិជ្ជកម្មទាំងនោះនឹងត្រូវជំនួសឲ្យចម្ការវិលជុំអចិន្ត្រៃយ៍។ ប៉ុន្តែជាជាងការវិវត្តបន្តិចម្តងៗ ការគាំ ទ្ររបស់រដ្ឋាភិបាលបានផ្តោតជាសំខាន់តែទៅលើការផ្លាស់ប្តូរមួយដ៏ឆាប់រហ័សចំពោះ ការដាំដំណាំស្បៀងអាហារអចិន្ត្រៃយ៍ ឬផ្តោតលើប្រព័ន្ធដំណាំ និងដើមឈើឯករប្បកម្ម ពិសេសៗ និងចម្ការ (van Noordwijk et al 2008, Schmidt-Vogt et al 2009)។ ឧទាហរណ៍ នៅប្រទេសឥណ្ឌូនេស៊ី សហគមន៍បានប្រែក្លាយដីទុកទំនេរទៅជាចម្ការដូងប្រេង។ ចម្ការវិលជុំក៏កំពុងតែថយចុះដោយការប្រែក្លាយពីកសិកម្មទៅជាសកម្មភាព ពុំមែនជាកសិកម្ម រួមទាំងទម្រង់កសិកម្មបែបពាណិជ្ជកម្ម (ទាំងនៅក្នុងឡូត៍ដីទុកទំនេរ ឬដីដែលបានរៀបចំ) និង/ឬការងារដែលមិនមែនជាកសិកម្មទាំងស្រុង (Ziegler et al 2011)។

ទោះបីជាកសិកម្មពាណិជ្ជកម្មធ្វើឲ្យអតីតកសិករចម្ការវិលជុំទទួលបានប្រាក់ចំណេញច្រើនជាងមុន និងទទួលបានការប្រើប្រាស់សេវាកម្មអប់រំ និងសុខភាពច្រើនជាងមុនយ៉ាងណាក៏ដោយ ភាពងាយរងគ្រោះចំពោះការខាតបង់សេដ្ឋកិច្ចតាមរយៈការខូចខាតដំណាំនិងទីផ្សារ បានបង្កើនត្រលប់ជាមួយនឹងឯកទេសកម្ម។ ពិពិធភាពលំហូរផលិតកម្មនិងចំណូល ធ្វើឲ្យប្រសើរឡើងនូវល

ទ្ធភាពនៃការស្តារឡើងវិញនូវសេដ្ឋកិច្ចរបស់កសិករ។ ករណីនេះអាចទទួលបានតាមរយៈការគាំទ្រនូវការវិវត្តបន្តិចម្តងៗនៃដីទុកចោលទំនេរ ដែលមានទំនាក់ទំនងទៅនឹងការស្តារឡើងវិញនូវដីទុកទំនេរកសិរុក្ខកម្ម និងដីទុកទំនេរដែលរេចរិល ជាជាងការលើកកម្ពស់ប្រព័ន្ធឯករប្បកម្ម។

## 2. ការកាន់កាប់ដីអសុវត្ថិភាព

នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ រដ្ឋាភិបាលដាក់ការត្រួតពិនិត្យស្ទើគ្រប់តំបន់ព្រៃឈើទាំងអស់។ ប៉ុន្តែដីចម្ការវិលជុំនៅតែជាដីដែលពុំឃើញមាននៅក្នុងស្ថិតិព្រៃឈើនៅឡើយ បើទោះបីជាវាត្រូវបានកែសម្រួលដោយបទបញ្ញត្តិព្រៃឈើហើយក៏ដោយ។ រដ្ឋា ភិបាលមួយចំនួនធំមិនបានទទួលស្គាល់ដីទុកទំនេរចម្ការវិលជុំថាជាផ្នែកមួយនៃរូបភាព ទេសភាពកសិកម្មនោះទេ ប៉ុន្តែបែជាចាត់ទុកដីទុកទំនេរ ដូចជាប្រភេទព្រៃរេចរិលឬជាដីត្រូវបានបោះបង់ចោលទៅវិញ។ បើទោះជាដីទុកទំនេរគ្របដណ្តប់រាប់លានហិចតាក៏ដោយ វាមិនបានត្រូវកត់សម្គាល់នៅក្នុងប្រភេទដីប្រើប្រាស់ឡើយ។ បណ្តាសហគមន៍ដែលរស់នៅក្នុងតំបន់ព្រៃរបស់រដ្ឋ ស្ទើតែពុំអាចទទួលបាននូវសិទ្ធិកាន់កាប់ដីធ្លីជាផ្លូវការលើដីដែលពួកគេគ្រប់គ្រង។ កសិរុក្ខកម្ម និងដីទុកទំនេរដែលមានការគ្រប់គ្រងតិចតួច នៅតែពុំទាន់បានបែងចែកជាឯកច្ឆន្ទនៅលើផែនទីនានារបស់រដ្ឋាភិបាលនៅឡើយ។ កង្វះលទ្ធភាពផ្លូវច្បាប់ក្នុងការប្រើប្រាស់ដីទុកទំនេរ ដែលរដ្ឋបានចាត់ទុកថាជាប្រភេទព្រៃឈើ ជម្រុញឲ្យកសិករកាប់ឆ្ការខុសច្បាប់ឡើងវិញនូវដីវាលទុកទំនេររបស់ពួកគេ ឬធ្វើការដាំដុះជាអចិន្ត្រៃយ៍។

### ឧទាហរណ៍ពីប្រទេសហ្វីលីពីន

នៅប្រទេសហ្វីលីពីន សេចក្តីថ្លែងការស្តីពីការទប់ស្កាត់ចម្ការវិលជុំមានការគាំទ្រដោយច្បាប់ គោលនយោបាយ និងការអនុវត្ត ដែលស្វែងរកជនមានទោសឧក្រិដ្ឋ និងកម្ចាត់ចោលនូវការអនុវត្តចម្ការវិលជុំ។ នៅតំបន់ខ្ពង់រាប ជនចំណាកស្រុកក្នុងប្រទេស ដែលមានប្លង់កម្មសិទ្ធដីធ្លីសុវត្ថិភាព អាចពង្រីកការដាំដុះដំណាំស្រូវវស្សាបាន ចំណែកឯសហគមន៍ជនជាតិដើមភាគតិច ឬជនក្រីក្របានចាកចេញទៅធ្វើចម្ការវិលជុំនៅលើដីឡូត៍ដែលមានសិទ្ធប្រើប្រាស់។ ជាលទ្ធផល ការធ្វើចំណាកស្រុកទៅកាន់តំបន់ខ្ពង់រាប ធ្វើឲ្យមានផលលំបាកផ្នែកសេដ្ឋកិច្ចសង្គម ដែលចេះតែកើនឡើងសម្រាប់ក្រុមជនជាតិដើមភាគតិច (Suarez and Sajise 2010) និងមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថានពីប្រពលកម្មទាំងនេះ។ សូម្បីតែក្នុងចំណោមក្រុមជនជាតិដើមភាគតិចខុសៗគ្នា ក៏ការដាក់សម្ពាធក្នុងការបង្កើនផលិតភាពដើម្បីឆ្លើយតបទៅនឹងការកើនឡើងនូវចំនួនប្រជាជន បាននាំឲ្យមានការធ្លាក់ចុះនូវនិរន្តរភាពនៃប្រព័ន្ធចម្ការវិលជុំរបស់ពួកគេ។



រូបភាព៖ World Agroforestry/Prasit Wangpakapattanawong

## 3. និរន្តរភាពកសិរុក្ខកម្មដីទុកទំនេរ-ចម្ការវិលជុំ

មុខងារប្រព័ន្ធចម្ការវិលជុំបែបប្រពៃណី ខុសគ្នាពីរបៀបដែលជនចំណាកស្រុកក្នុងប្រទេសនិងធុរកិច្ចកសិកម្មប្រើប្រាស់ដី ដែលមានន័យថាជាការកែប្រែព្រៃទៅជាដំណាំប្រចាំឆ្នាំ និងពហុវត្សដោយពុំមានការសន្យាចំពោះនិរន្តរភាព។

ប្រព័ន្ធចម្ការវិលជុំចម្រុះរបស់កសិកម្ម និងព្រៃឈើរួមបញ្ចូលដីវាលកសិកម្មជាមួយនឹងកសិរុក្ខកម្មចម្រុះដាំដុះឡើងវិញ នាំមកនូវសេវាកម្មស្ថានប្រព័ន្ធដែលជាផ្នែកមួយដ៏សំខាន់សម្រាប់សុខុមាលភាពនិងការចិញ្ចឹមជីវិតរបស់ប្រជាជននិងសម្រាប់និរន្តរភាពបរិស្ថាន។ ពួកវាជាអ្នកការពារដ៏សំខាន់នៃនានាភាពរបស់ប្រភេទរុក្ខជាតិសាមីដ៏មានប្រយោជន៍និងសត្វព្រៃ។

ប្រព័ន្ធទាំងនេះអាចមើលឃើញថាមានលក្ខណៈល្អប្រសើរជាងការធ្វើកសិកម្មបែបប្រពៃណីព្រោះបើទោះបីជាទទួលបានទិន្នផលទាបក្នុងមួយឯកតានៃផ្ទៃដីក៏ដោយ ក៏ប្រព័ន្ធទាំងនេះជួយការពារដី ហើយមិនតម្រូវឲ្យមានការប្រើប្រាស់ជាតុចូលដែលពឹងផ្អែកលើថាមពលឥន្ទនៈដែលមានតម្លៃថ្លៃនិងបង្កឲ្យមានផលប៉ះពាល់ ដូចជាជីពាណិជ្ជកម្ម ថ្នាំសម្លាប់ស្មៅ ឬថ្នាំសម្លាប់សត្វល្អិតជាដើម (SuarezandSajise 2010, Dressler et al  2014)។

កសិរុក្ខកម្មដីទុកទំនេរ-ចម្ការវិលជុំ ផ្ទុយពីកសិកម្មពនេចរនិងឯកវប្បកម្មដែលអនុវត្តជាទូទៅ នឹងនាំឲ្យមានការប្រើប្រាស់ដីជាអចិន្ត្រៃយ៍ដោយពុំមានការដុត ឬធ្វើឲ្យមានការខូចខាតដីឡើយ។ ប្រព័ន្ធនេះគឺជាវិធីសាស្ត្រកែលម្អយ៉ាងមានប្រសិទ្ធភាពដែលបានប្រើប្រាស់ដើម្បីបម្លែងដីរេចរិលឲ្យទៅជាតំបន់ដែលមានផលិតភាពនិងនិរន្តរភាព។ ដោយប្រើប្រាស់នូវចលនាតំណភាពធម្មជាតិ ប្រភេទដំបូងត្រូវបានគាំពារដើម្បីធ្វើការគ្រប់គ្រង និងស្តារឡើងវិញនូវតំបន់ទីវាលចំហនានា។ ប្រព័ន្ធដាំដំណាំប្រពលវប្បកម្មដែលជំនួសដោយចម្ការវិលជុំ ក៏បានរួមចំណែកកាត់បន្ថយកាបូនស្តុកសរុបទូទៅផងដែរ (Ziegler et al 2010)។ កិច្ចជជែកពិភាក្សាលើគោលនយោបាយអន្តរជាតិទាក់ទងទៅនឹង REDD+ បានគាំទ្រដល់តួនាទីរបស់ទេសភាពព្រៃឈើចម្រុះដែលបានផ្តល់នូវសេវាកម្មអេកូឡូស៊ីនៅក្នុងការប្រើប្រាស់ដីរបស់គ្រួសារកសិករតូចៗ រួមទាំងចម្ការវិលជុំ និងកសិរុក្ខកម្មផងដែរ។ បើទោះជាយ៉ាងនេះក្តី គំនិតផ្តួចផ្តើមអភិបាលកិច្ចជាសកល និងរដ្ឋាភិបាលថ្នាក់ជាតិបន្តប្រឹងប្រែងជម្រុញឲ្យមានការផ្លាស់ប្តូរចម្ការវិលជុំទៅជាប្រភេទដីផ្សេងទៀត ការប្រើប្រាស់ ពិចារណាទៅលើការកំណត់លើព្រៃឈើ ការចុះខ្សោយនៃជីវភាពរស់នៅ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឲ្យបានច្រើនជាងការប្រើប្រាស់ដីដទៃទៀត។  យ៉ាងណាក៏ដោយប្រព័ន្ធកសិរុក្ខកម្មផ្តល់នូវការស្តុកទុកកាបូនដ៏មានប្រសិទ្ធភាពទាំងលើនិងក្រោមដីជីវម៉ាស។

## 4. ការផ្លាស់ប្តូរដោយនិរន្តរភាព

ទន្ទឹមនឹងការផ្លាស់ប្តូរការប្រើប្រាស់ដីសំខាន់ៗនៅតែបន្តកើតមានក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏នៅមានភាពមិនច្បាស់លាស់គួរឲ្យកត់សម្គាល់ជុំវិញផលប៉ះពាល់ដែលការប្រើប្រាស់ដី ជាអាទិ៍សម្រាប់ប្រព័ន្ធប្រពលកម្ម បម្លាស់ប្តូរដំណាំ និងព្រៃការពារជាដើម កើតមានទៅលើសុវត្ថិភាពនៃការចិញ្ចឹមជីវិត និងសេវាកម្មអេកូឡូស៊ី បើប្រៀបធៀបទៅនឹងប្រព័ន្ធចម្ការវិលជុំដែលមានស្រាប់។(Dressler et al 2014)។

ការប្រែក្លាយពីប្រព័ន្ធចម្ការវិលជុំទៅជាដីប្រើប្រាស់ផ្សេងៗទៀត អាចប៉ះពាល់អវិជ្ជមានដល់ជីវចម្រុះ និងគុណភាពដី ព្រោះដីត្រូវបានប្រើប្រាស់ជាលក្ខណៈប្រពលវប្បកម្មច្រើនជាងមុន (Cruz 2015)។ កសិករអាចទទួលបានបទពិសោធន៍ផលប៉ះពាល់អវិជ្ជមានលើសុវត្ថិភាពស្បៀងអាហារ ការប្រើប្រាស់ដី និងអត្តសញ្ញាណវប្បធម៌។ ការផ្លាស់ប្តូរតាមរយៈការវិវត្តបន្តិចម្តងៗទៅជាប្រព័ន្ធកសិរុក្ខកម្មមានសក្តានុពលយ៉ាងធំធេងសម្រាប់លើកកម្ពស់ការអនុវត្តចម្ការវិលជុំ និងផ្តល់ជាជម្រើសជំនួស សម្រាប់ប្រព័ន្ធដំណាំនិងដើមឈើឯកវប្បកម្មនិងឯកទេសកម្មកម្រិតខ្ពស់។

| | ឯកទេសកម្មប្រព័ន្ធឯកវប្បកម្ម | កសិរុក្ខកម្មដីទុកទំនេរចម្ការវិលជុំ |
|---|---|---|
| **ចំណុចខ្លាំង** | សុខុមាលភាពសេដ្ឋកិច្ចរបស់កសិករមានការកើនឡើងតាមរយៈការធ្វើឯកទេសកម្ម។ | • ពិពិធភាពផលិតកម្មធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពស្តារឡើងវិញរបស់កសិករ បំពេញបន្ថែមជីវភាពរស់នៅ និងការកែលម្អរបបអាហារ។<br>• រក្សានូវសេវាកម្មអេកូឡូស៊ីសំខាន់ៗ<br>• ទុកបម្រុងសម្រាប់ការប្រើប្រាស់ដីជាអចិន្ត្រៃយ៍ និងផ្តល់ឲ្យនូវការស្តុកទុកកាបូន |
| **ចំណុចខ្សោយ** | • កសិករកាន់តែងាយរងគ្រោះចំពោះការខាតបង់ផ្នែកសេដ្ឋកិច្ច តាមរយៈការខូចខាតដំណាំ ឬការប្រែប្រួលទីផ្សារ។<br>• ជំនួសព្រៃឈើដោយពុំមានការធានាលើការប្រើប្រាស់ដីដោយនិរន្តរភាព។<br>• ប្រើប្រាស់ថាមពលឥន្ធនៈមានតម្លៃថ្លៃ និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរ (ជីថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅ)។ | • សក្តានុពលដែលមិនបានប្រើប្រាស់ឲ្យអស់លទ្ធភាព និងប្រើប្រាស់ពុំមានប្រសិទ្ធភាព។<br>• ចាត់ទុកជាដីបោះបង់ចោល ឬរេចរិល។ |
| **កាលានុវត្តភាព** | គោលនយោបាយដែលគាំទ្រដល់ការពង្រីកយ៉ាងឆាប់រហ័ស។ | ការវិវត្តបន្តិចម្តងៗសម្រាប់ការស្តារឡើងវិញនូវដីទុកទំនេររេចរិល។ |
| **ការគម្រាមកំហែង** | • និរន្តរភាពបរិស្ថានក្នុងកម្រិតទាប។<br>• ថយចុះផលិតកម្មទៅតាមពេលវេលាតាមរយៈតំហយភាពដី | • ពុំបានបញ្ជាក់បង្ហាញនៅក្នុងប្រភេទប្រើប្រាស់ដី។<br>• សន្តិសុខក្នុងការកាន់កាប់ដីនៅទាបនិងកង្វះនូវការទទួលស្គាល់។<br>• ផ្លាស់ប្តូរឆាប់រហ័សទៅជាការដាំដំណាំអចិន្ត្រៃយ៍ ឬឯកវប្បកម្មឯកទេសកម្ម។ |

រូបភាព1៖ វិភាគលើចំណុចខ្លាំ ចំណុចខ្សោយ កាលានុវត្តភាព និងការគម្រាមកំហែងនៃប្រព័ន្ធឯកវប្បកម្មឯកទេសកម្ម ទល់នឹងប្រព័ន្ធកសិរុក្ខកម្មដីទុកទំនេរចម្ការវិលជុំ។



រូបភាព៖ World Agroforestry



ដំណាំពោតស្ថិតក្នុងតំបន់ចម្ការវិលជុំ | រូបភាព៖ World Agroforestry/Mr.Sarun Jit-aree

# អនុសាសន៍

តាមទស្សនៈជាយុទ្ធសាស្ត្ររបស់ស្ថាប័នស្បៀងអាហារកសិកម្មនិងព្រៃឈើអាស៊ាន បណ្តារដ្ឋជាសមាជិកអាស៊ានអាចអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ដាក់ចេញនូវគោលនយោបាយលើកកម្ពស់ប្រព័ន្ធកសិរុក្ខកម្មចម្ការវិលជុំប្រើប្រាស់នូវចលនានៃតំណភាពចំពោះដីទុកឲ្យទំនេរដែលមិនបានប្រើប្រាស់ និងមានតំហយភាពឲ្យដូចជាផ្នែកមួយនៃការគ្រប់គ្រងដី និងព្រៃដោយនិរន្តរភាព។
- ពង្រីកកសិរុក្ខកម្មនៅលើដីទុកទំនេរ និងរាយការណ៍ដែលជាវិធានការសមស្របថ្នាក់ជាតិ និងការរួមចំណែកដាច់ខាត ទៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (NAMA និង NDC)។
- កសាងសមត្ថភាពផ្តល់នូវជំនួយបច្ចេកទេសនិងគាំទ្រផ្នែកហិរញ្ញវត្ថុដល់កសិករចម្ការវិលជុំ ដើម្បីអភិវឌ្ឍប្រព័ន្ធកសិរុក្ខកម្ម។ ផ្តល់ការប្រើប្រាស់ជីវករគុណភាពខ្ពស់ លើកកម្ពស់ចំណេះដឹងការគ្រប់គ្រងដើមឈើបង្កើនជំនាញ និងព័ត៌មាន។
- គាំទ្រដល់ការអភិវឌ្ឍខ្សែចង្វាក់តម្លៃរួមបញ្ចូលគ្នាសម្រាប់ផលិតផលកសិរុក្ខកម្ម ដោយផ្តល់ព័ត៌មានទីផ្សារគ្រប់គ្រាន់ ទន្ទឹមនឹងការផ្សារភ្ជាប់កសិករចម្ការវិលជុំជាមួយនឹងទីផ្សារ ព្រមទាំងការលើកកម្ពស់សមាហរណកម្មតំបន់។
- ធានាសិទ្ធកាន់កាប់ដីរបស់កសិករចម្ការវិលជុំទៅលើដីចម្ការវិលជុំ តាមរយៈការលើកទឹកចិត្តក្រោមការការឧបត្ថម្ភពីរដ្ឋ (ឧទាហរណ៍៖ ការគ្រប់គ្រងព្រៃឈើដោយពឹងផ្អែកលើសហគមន៍) និងកំណែទម្រង់ដីកសិកម្មជាមួយគោលបំណងលើកទឹកចិត្តដល់ការវិនិយោគកសិរុក្ខកម្មរយៈពេលវែង។

# កំណត់សម្គាល់បញ្ចប់

1. បច្ចេកស័ព្ទមានន័យ □ទីទួល□ (taung) □ដាំដុះ□ (ya) ត្រូវបានបង្កើតឡើងប្រទេសភូមាក្នុងទសវត្សរ៍ឆ្នាំ 1850 ដោយលោក Dietrich Brandis (1824□1907) ជាព្រៃឈើវិទូជនជាតិអាល្លឺម៉ង់ ដែលជាអ្នកធ្វើការជាមួយនិងស្ថាបនសេវាកម្មព្រៃឈើចក្រភពអង់គ្លេសនៅភូមា។ តាមប្រព័ន្ធ Taungya កសិករត្រូវបានអនុញ្ញាតឲ្យដាំដំណាំនៅក្នុងចម្ការដែលបានបង្កើតថ្មី (Watson 2013)។
2. ក្នុងធម្មជាតិ បណ្តុំនៃរុក្ខជាតិលូតលាស់បន្តដុះលូតលាស់ពីមួយជំនាន់ទៅមួយជំនាន់ឥតដាច់ ហៅថា □តំណភាពធម្មជាតិ□ (Goetsch 1992) ចលនានៅតំណភាពធម្មជាតិគឺជាលំនាំបែបធម្មជាតិនៃការផ្លាស់ប្តូរនូវទម្រង់របស់ប្រភេទនានា តួយ៉ាងដូចជាបន្ទាប់ពីមានភ្លើងឆេះព្រៃកើតឡើង។

## ឯកសារយោង

Cruz A. 2015. *The past, present and future of swidden agriculture*. Nairobi: World Agroforestry Centre (ICRAF). http://blog.worldagroforestry.org/index.php/2015/05/07/the-past-present-and-future-of-swidden-agriculture/

Dressler W, Wilson D, Clendenning J, Cramb R, Mahanty S, Lasco R, Gevana D. 2015. Examining how long fallow swidden systems impact upon livelihood and ecosystem services outcomes compared with alternative land uses in the uplands of Southeast Asia. *Journal of Development Effectiveness* 7(2):210–229.

Lasco RD, Visco RG, Pulhin JM. 2001. Secondary forests in the Philippines: formation and transformation in the 20th century. *Journal of Tropical Forest Science* 13(4):652–670.

Fox J, Fujita Y, Ngidang D, Peluso N, Potter L, Sakuntaladewi N, Sturgeon J, Thomas D. 2009. Policies, political economy and swidden in Southeast Asia. *Human Ecology* 37:305–322.

Goetsch E, Colinas FT. 1992. *Natural succession of species in agroforestry and in soil recovery.* Paper. http://www.agrofloresta.net/artigos/agroforestry_1992_gotsch.pdf. Accessed 23/05/2016.

Li P, Feng Z. 2016. Extent and area of swidden in montane mainland Southeast Asia: estimation by multi-step thresholds with Landsat-8 OLI data. *Remote Sensing* 8.

Michon G. 2005. *Domesticating forests: how farmers manage forest resources*. Bogor, Indonesia: Center for International Forestry Research.

Schmidt-Vogt D, Leisz SJ, Mertz O, Heinemann A, Thiha T, Messerli P, Dao TM. 2009. An assessment of trends in the extent of swidden in Southeast Asia. *Human Ecology* 37(3):269–280.

Snelder D, Lasco R, eds. 2008. *Smallholder tree growing for rural development and environmental services: lessons from Asia*. Advances in Agroforestry 5. Dordrecht, Netherlands: Springer.

Suarez RK, Sajise PE. 2010. Deforestation, swidden agriculture and Philippine biodiversity. *Philippine Science Letters* 3(1):91–99.

van Noordwijk M, Mulyoutami E, Sakuntaladewi N, Agus F. 2008. *Swiddens in transition: shifted perceptions on shifting cultivators in Indonesia*. Bogor, Indonesia: World Agroforestry Centre (ICRAF) Southeast Asia Regional Program.

Watson C. 2013. *New agroforestry horizons in Myanmar: the challenge of slash and burn.* Nairobi: World Agroforestry Centre (ICRAF). http://blog.worldagroforestry.org/index.php/2013/12/20/new-horizons-for-icraf-in-myanmar-the-challenge-of-slash-and-burn/

Ziegler AD, Fox JM, Webb EL, Padoch C, Leisz SJ, Cramb R, Vien TD. 2011. Recognizing contemporary roles of swidden agriculture in transforming landscapes of Southeast Asia. *Conservation Biology* 25(4):846.

## អ្នកនិពន្ធ

Sébastien de Royer (s.royer@cgiar.org)
Anantika Ratnamhin (a.ratnamhin@cgiar.org)
Prasit Wangpakapattanawong (p.wang@cgiar.org)

## សម្រង់ត្រឹមត្រូវ

De Royer S, Ratnamhin A, Wangpakapattanawong P. 2018. *Swidden-fallow agroforestry for sustainable land use* (in Khmer). Policy Brief No. 98. Agroforestry options for ASEAN series No.2. Bogor, Indonesia: World Agroforestry (ICRAF) Southeast Asia Regional Program; Jakarta, Indonesia: ASEAN-Swiss Partnership on Social Forestry and Climate Change.

For more information, contact

**AWG-SF Secretariat**
Manggala Wanabhakti Building, Block VII, 4th Floor,
Jalan Gatot Subroto, Senayan, Jakarta 10270, Indonesia
Tel: +62-21-5703246, ext 478 - Fax: +62-21-5730136

**World Agroforestry (ICRAF)**
**Southeast Asia Regional Program**
Jl. CIFOR, Situ Gede, Sindang Barang, Bogor 16115
[PO Box 161, Bogor 16001] Indonesia
Tel: +(62) 251 8625415 | Fax: +(62) 251 8625416
Email: icraf-indonesia@cgiar.org
www.worldagroforestry.org/region/southeast-asia
blog.worldagroforestry.org

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

**ASEAN Working Group on Social Forestry (AWG-SF)** is government-initiated network that aims to strengthen social forestry in Southeast Asia through the sharing of information and knowledge. AWG-SF established by the Association of Southeast Asian Nations (ASEAN) Senior Officials on Forestry (ASOF) in August 2005, linking government forestry policy makers directly with the civil society organizations, research organizations, academia, private sector, and all of whom share a vision of promoting social forestry policy and practices in ASEAN.

The **ASEAN-Swiss Partnership on Social Forestry and Climate Change (ASFCC)** is a Partnership Programme of ASEAN that aims to contribute to the ASEAN Mandate and Policy Framework through support for the ASEAN Working Group on Social Forestry and the ASEAN Multi sectoral Framework on Climate Change towards Food Security.